


# បុណ្យកឋិនទានសាមគ្គី

**យើង**ខ្ញុំព្រះករុណា អាត្មាភាព ខ្ញុំបាទ នាងខ្ញុំជាគណៈកម្មការ **សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោមប្រចាំអឺរ៉ុប និងគណៈកម្មការអាចារ្យវត្តមង្គលសោភ័ណ្ឌ ព្រមទាំងពុទ្ធបរិស័ទខេត្តប្ល័រ្ស ប្រទេសបារាំង ។**

មានកិត្តិយសសូមនិមន្តព្រះករុណាគ្រប់ព្រះអង្គនិងសាធុសប្បុរសជនទាំងជិតឆ្ងាយនិងបងប្អូនញាតិមិត្តគ្រប់ទិសទីទាំងអស់រីករាយចូលរួមធ្វើបុណ្យកឋិនទានសាមគ្គីដោយមេត្រីភាព **មានតែឃុំចូលរួមជខ្មែរចូលវត្តមង្គលសោភ័ណ្ឌខេត្តប្ល័រ្ស ។**

**នៅថ្ងៃសៅរ៍ទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៤** នៅអាស័យដ្ឋានសាលបុណ្យ ៖ **SALLE DES FETES DE BEAUCE ; 01 RUE DUPRE 41000 BLOIS ( FRANCE ) ;**

**Tel fixe et Mobile : 02 54 56 00 96 ; 06 64 59 87 84 ; E-mail : uoongsok@gmail.com ;chakraphop1@gmail.com Facebook:sokuoong ;**

Sok Vénérable Uoong. **កម្មវត្ថុ ៖** ប្រមូលថវិកាបាននិងជាវផ្ទះសម្រាប់សាងវត្តខ្មែរទុកឲ្យព្រះសង្ឃគង់និងពុទ្ធបរិស័ទទូទៅធ្វើបុណ្យ ។

## កម្មវិធីបុណ្យ

**ព្រឹកថ្ងៃសៅរ៍ទី ០១ ខែ ១១ ឆ្នាំ ២០១៤ ត្រូវនិងថ្ងៃសៅរ៍ ១០ កើត ខែ កត្តិក ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨**

ម៉ោង ០៩៖៣០ នាទី ការដែលភ្ញៀវអញ្ជើញមកដល់ ។

ម៉ោង ១០៖៣០ នាទី ជួបជុំពុទ្ធបរិស័ទនមស្សការព្រះរតនៈត្រៃ សមាទានសីល រាប់បាត្រ វេរភត្តប្រគេនដល់ព្រះសង្ឃ ។

ម៉ោង ១២៖៣០ នាទី ភ្ញៀវពិសារភោជនាហាររួមគ្នាយ៉ាងសប្បាយ ។ ម៉ោង ១៣៖៣០ នាទីហែរត្រៃអង្គកឋិនទានសាមគ្គីបីជុំក្នុងសាលបុណ្យជានិមិត្តរូបរួចហើយយកមកដំកល់ចំពោះមុខសង្ឃជាសង្ឃទានស្មោះ រួចហើយវេរប្រគេនអង្គកឋិនទានចំពោះព្រះសង្ឃនិមន្តធម្មកថឹកសម្តែងព្រះធម៌ទេសនាត្រៃបី ។ ម៉ោង១៥៖៣០នាទីជាកិច្ចការរបស់ព្រះសង្ឃក្រាលគ្រងកឋិនទានសាមគ្គីព្រះសង្ឃសូត្រជយន្តោជាកិច្ចសំរេចបុណ្យ ។អាស្រ័យដូចបានប្រគេននិងជំរាបខាងលើរួចហើយសូមនិមន្តនិងអញ្ជើញចូលរួមឲ្យបានច្រើនកុះករនិងញ៉ាំងពិធីបុណ្យឲ្យបានឱឡារឹកហើយនិងអនុមោទនាភាគផលរៀងៗខ្លួន **សូមអនុមោទនាបុណ្យ**! **កម្មវិធីពេលល្ងាចចាប់ផ្តើមពីម៉ោង ១៩ ទៅ និងប្រគល់ឲ្យមានកម្មវិធីតន្ត្រីចម្រៀងនិងមានរាំច្រៀងតន្ត្រីខារ៉ាអូខេ NON STOP រហូតដល់ម៉ោង ០២ ភ្លឺ ថ្ងៃអាទិត្យទី ០២ ខែ ១១ ឆ្នាំ២០១៤** ហើយបើសិនលោកលោកស្រីអ្នកនាងកញ្ញាមានចិត្តស្រឡាញ់វិស័យចំរៀងសីល្បៈ សូមអញ្ជើញឡើងច្រៀងលេងកំសាន្ត ( **សូមលោកលោកស្រីអ្នកនាងកញ្ញាយក DVD និង VCD ផ្ទាល់ខ្លួនមកជាមួយផង** ) ។ **សូមជំរាបថា ៖** ក្នុងកម្មវិធីបុណ្យកឋិនទានសាមគ្គីនិងមានលក់ភេសជ្ជៈនិងម្ហូបនៅកន្លែង ដោយតម្លៃសមរម្យបានចំណេញប្រគេនវត្តទុកកសាងវត្តខ្មែរនៅខេត្តប្ល័រ្សប្រទេសបារាំង ចំណែកក្លោងទ្វារចូលតាមសទ្ធាជ្រះថ្លា ។ **សូមអរព្រះគុណ!!! សូមអរគុណ ..! សូមអនុមោទនាបុណ្យ ..! សូមប្រគេននិងជំរាប ៖**

**ក្នុងមួយត្រៃបវារណា ១០០ អឺរ៉ូ ( បើគិតជាដុល្លា សូមបវារណា ១៤០ ដុល្លា ) សូមញាតិញោមចុះឈ្មោះពីថ្ងៃនេះតទៅ ។**